**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

# សារលិខិតអបអរសាទរ

## សូមក្រាបបង្គំទូលថ្វាយ

## សម្តេចព្រះមហាសុមេធាធិបតី អំ លឹមហេង សម្តេចព្រះសង្ឃនាយក

## គណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា

**សម្តេចព្រះមហាសុមេធាធិបតី ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត !**

ខ្ញុំព្រះករុណាខ្ញុំ និងភរិយា សូមសម្តែងនូវអំណរសាទរប្រកបដោយមនោសញ្ចេតនាវីករាយឥតឧបមា ប្រគេនចំពោះ **សម្តេចព្រះមហាសុមេធាធិបតី ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ក្នុងឱកាសដែល**សម្តេច** ត្រូវបាន **ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ប្រោសព្រះរាជទានត្រាស់បង្គាប់ ដំឡើង និងតែងតាំងព្រះឋានៈជា **សម្តេចព្រះមហាសុមេធាធិបតី សម្តេចព្រះសង្ឃនាយក គណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា។**

ព្រះគោរមងារ និងព្រះឋានៈថ្មីនេះ ពិតជាស័ក្តិសមបំផុតចំពោះ **សម្តេចព្រះមហាសុមេធាធិបតី** ដែលមានស្នាព្រះហស្ត ព្រះគុណូបការៈដ៏ធំធេង បានខិតខំប្រឹងប្រែងប្រកបដោយឆន្ទៈមោះមុត លះបង់ព្រះកាយពល ព្រះបញ្ញាញាណ ដោយមិនខ្លាចនឿយហត់ក្នុងព្រះបុព្វហេតុជាឧត្តមប្រយោជន៍សម្រាប់ជាតិ និងក្នុងវិស័យព្រះពុទ្ធសាសនា។

នៅក្នុងវពោកាសដ៏ថ្លៃថ្លាឧត្តុង្គឧត្តមនេះ ខ្ញុំព្រះករុណាខ្ញុំ និងភរិយា សូមលើកហត្ថប្តូងសួងដល់គុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតាថែរក្សាព្រះរាជាណាចក្រកម្ពុជា ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ សូមយាងអភិបាលបីបាច់ថែរក្សា និងប្រោះព្រំនូវសព្វសាធុការពរ ប្រគេនចំពោះ **សម្តេចព្រះមហាសុមេធាធិបតី ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** សូមមានព្រះសុខភាពល្អបរិបូរណ៍ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា វាងវៃ ព្រះជន្មាយុយឺនយូរ និងសមប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចព្រះមហាសុមេធាធិបតី សម្តេចព្រះសង្ឃនាយក គណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា** ព្រះមេត្តាទទួលនូវអភិវន្ទនកិច្ចជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ពីខ្ញុំព្រះករុណាខ្ញុំ និងភរិយា។

ថ្ងៃចន្ទ ៩កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៤

**នាយឧត្តមសេនីយ៍ ទៀ សីហា**